ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១៧៧៣ សហវ.ប្រក

# ប្រកាស
## ស្តីពី
## ការបង្កើតក្រុមការងារគ្រប់គ្រងចំណូលពីកម្រៃសេវាអាកាសចរស៊ីវិល

### ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦ /១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨២២/០១០ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញសេចក្តីជូនដំណឹងលេខ ១០៥ សជណ.ពហ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៨ ស្តីពីការកំណត់កម្រៃសេវាអាកាសចរស៊ីវិល (Civil Aviation Fee - CAF)
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើតក្រុមការងារគ្រប់គ្រងចំណូលពីកម្រៃសេវាអាកាសចរស៊ីវិល ដែលមានសមាសភាពដូចខាងក្រោម÷

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម **ទី តាយី** | រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (កសហវ) | ប្រធាន |
| ២- | ឯកឧត្តម **ជា អ៊ូន** | រដ្ឋលេខាធិការប្រចាំការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល(រលអស) | អនុប្រធាន |
| ៣- | ឯកឧត្តម **អ៊ួន ម៉ុនឃាក់** | អនុរដ្ឋលេខាធិការ កសហវ | អនុប្រធានប្រចាំការ |
| ៤- | ឯកឧត្តម **ទ៉ាន់ ចន្ទី** | ជំនួយការ និងជាប្រធាននាយកដ្ឋានដឹកជញ្ជូនតាមផ្លូវអាកាស នៃ រលអស | សមាជិក |
| ៥- | ឯកឧត្តម **ស៊ុន ម៉ុនថាត** | ជំនួយការ និងជាប្រធាននាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ នៃ រលអស | សមាជិក |
| ៦- | ឯកឧត្តម **ឆាយ វណ្ណៈ** | ជំនួយការ និងជាប្រធានការិយាល័យ នៃនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ នៃ រលអស | សមាជិក |
| ៧- | លោក **ឌេន ផាត** | អគ្គនាយករង នៃនិយ័តករគណនេយ្យនិងសវនកម្ម (ន.គ.ស.) | សមាជិក |
| ៨- | លោក **ហ៊ត់ ធានី** | ប្រធាននាយកដ្ឋានចំណូលសាធារណៈ នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ (អ.ទ.ច.) នៃ កសហវ | សមាជិក |
| ៩- | លោក **ទេព វណ្ណដារ៉ា** | អនុប្រធាននាយកដ្ឋានចំណូលសាធារណៈ នៃ អ.ទ.ច. នៃ កសហវ | សមាជិក |
| ១០- | លោក **គង់ ពិសោរ** | ប្រធានការិយាល័យនៃនាយកដ្ឋានដឹកជញ្ជូនតាមផ្លូវអាកាសនៃរលអស | សមាជិក |
| ១១- | លោក **សាន គីមហ៊ាង** | ប្រធានការិយាល័យ នៃនាយកដ្ឋានចំណូលសាធារណៈ នៃ អ.ទ.ច. នៃកសហវ | សមាជិក |
| ១២- | លោក **សោម យ៉ាន់សាម៉ូ** | អនុប្រធានការិយាល័យ នៃនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ នៃរលអស | សមាជិក |
| ១៣- | លោក **ទ៉ាន់នី សាំងរ៉ាឌីន** | អនុប្រធានការិយាល័យ នៃនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ នៃរលអស | សមាជិក |
| ១៤- | លោក **ទី ទិទ្ធ** | អនុប្រធាននាយកដ្ឋានបច្ចេកទេស នៃ ន.គ.ស. | លេខាធិការ |

**ប្រការ២ .-**

ក្រុមការងារមានតួនាទី និងភារកិច្ច ដូចខាងក្រោម÷

- គ្រប់គ្រងចំណូលពីកម្រៃសេវាអាកាសចរស៊ីវិល ដែលប្រមូលបានពីភ្ញៀវទេសចរជាតិ និងអន្តរជាតិ តាមរយៈក្រុមហ៊ុនអាកាសចរណ៍
- ពិនិត្យផ្ទៀងផ្ទាត់ចំណូលដែលប្រមូលបានពីកម្រៃសេវាអាកាសចរស៊ីវិល ជាប្រចាំ
- សហការជាមួយស្ថាប័នពាក់ព័ន្ធ សិក្សាឱ្យបានស៊ីជម្រៅ និងគ្រប់ជ្រុងជ្រោយអំពីយន្តការ និងនីតិវិធី ដើម្បីកៀរគរចំណូលពីកម្រៃសេវាអាកាសចរស៊ីវិល ឱ្យអស់សក្តានុពល

- ធ្វើរបាយការណ៍ស្ថានភាពស្តីពីការអនុវត្តចំណូលពីកម្រៃសេវាអាកាសចរស៊ីវិល ដាក់ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យ សម្រេច ឬ ផ្តល់អនុសាសន៍ការណែនាំដ៏ខ្ពង់ខ្ពស់។

ទន្ទឹមនឹងនេះ ក្រុមការងារក៏មានសិទ្ធិអញ្ជើញក្រុមហ៊ុនអាកាសចរណ៍ទាំងអស់ ដែលបាន និងកំពុងធ្វើអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ចូលរួមប្រជុំតាមការចាំបាច់ ឬ ស្នើសុំផ្តល់ឯកសារពាក់ព័ន្ធនឹងចំនួនភ្ញៀវទេសចរ ដែលធ្វើដំណើរចេញពីអាកាសយានដ្ឋានទាំងអស់។

**ប្រការ៣ .-**

សមាសភាពនៃក្រុមការងារ ដែលមានចែងក្នុងប្រការ១ នៃប្រកាសនេះ ត្រូវចូលរួមប្រជុំ តាមការអញ្ជើញរបស់ឯកឧត្តមប្រធានក្រុមការងារ។ នៅពេលប្រធានក្រុមការងារអវត្តមាន អនុប្រធានក្រុមការងារត្រូវដឹកនាំការប្រជុំតាមកាលបរិច្ឆេទដែលបានកំណត់។

**ប្រការ៤ .-**

ប្រកាសលេខ១៧៤ សហវ.ប្រក ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៩ ស្តីពីការបង្កើតក្រុមការងារគ្រប់គ្រងចំណូលពីកម្រៃសេវាអាកាសចរស៊ីវិល ត្រូវទុកជានិរាករណ៍ និងជំនួសដោយប្រកាសនេះ។

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៥ .-**

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋាន ឬអគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ប្រធាន អនុប្រធាន អនុប្រធានប្រចាំការ និងសមាជិកក្រុមការងារគ្រប់គ្រងចំណូលពីកម្រៃសេវាអាកាសចរស៊ីវិល ដូចមានចែងក្នុងប្រការ១ ខាងលើ ព្រមទាំងស្ថាប័នពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហ ១៥កើត ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៦ ខែ មេសា ឆ្នាំ២០២៣

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

កន្លែងទទួល :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ